# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៥...អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

# ការបង្កើតតំបន់ព្រៃការពារអភិរក្សដីជំរាល

# ជួរភ្នំក្រវាញភាគកណ្តាល និង ជីវៈចំរុះ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៩/០៧ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឱ្យមានការកំណត់ និងការគ្រប់គ្រងព្រៃតំបន់ដីជំរាលនៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-បានឃើញក្រឹត្យ-ច្បាប់លេខ ៣៥ ក្រ.ច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០២

# ស ំ រ េ ច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតតំបន់ព្រៃការពារអភិរក្សជីវចម្រុះដំរីចូរភ្នំក្រវាញភាគកណ្ដាល និង ជីវៈចំរុះ ស្ថិតក្នុងខេត្តកោះកុង ពោធិសាត់ និង កំពង់ស្ពឺ ក្នុងគោលបំណង÷

-ការពារ និង អភិរក្សរុក្ខជាតិ និង សត្វព្រៃគ្រប់ប្រភេទ ជាពិសេសប្រភេទដែលកំពុងទទួលរងគ្រោះ និង ប្រភេទជិតផុតពូជ

-រក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាទីជំរកសំរាប់ការស្នាក់អាស្រ័យ និង ការបន្តពូជរបស់ប្រភេទសត្វព្រៃ

-សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ដើម្បីអភិវឌ្ឍ និង អភិរក្សដំរីជំរាល និង ជីវៈចំរុះ

-ការពារការហូរច្រោះ ទឹកជំនន់ រក្សានូវសុក្រឹតភាពនៃប្រភពទឹក និង គុណភាពទឹក ទប់ទល់ការបាត់បង់ជីជាតិរបស់ដី

-ជំរុញការអប់រំ ផ្សព្វផ្សាយ និង អភិវឌ្ឍសហគមន៍

-ថែរក្សា និង អភិវឌ្ឍវិស័យទេសចរធម្មជាតិ

-ថែរក្សានូវកេរ្តិ៍តំណែលវប្បធម៌ប្រវត្តិសាស្ត្រ ដែលមាននៅក្នុងតំបន់ ។

**មាត្រា ២.-**

-តំបន់ព្រៃការពារអភិរក្សដំរីជំរាលជួរភ្នំក្រវាញភាគកណ្ដាល និង ជីវៈចំរុះ មានផ្ទៃក្រឡា ៤០១.៣១៣ហិកតា ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ ជាប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្ដាចំណុចគោល ដែលមាននិយាមកា: A(302658, 1330480) , B(311761, 1301421) , C(318825, 1300521) , D(325414, 1295388) , E(326736, 1294568) , F(326392, 1290679) , G(344602, 1304649) , H(346038, 1306077) , I(347281, 1304463) , J(350582, 1301355) , K(340987, 1286035) , L(344554, 1286035) , M(351233, 1286035) , N(358932, 1276257) , O(367052, 1277948) , P(371870, 1284576) , Q(377272, 1288840) , R(375178, 1292106) , S(374993, 1308969) , T(370710, 1334652) , U(368848, 1332530) , V(365227, 1333316) , W(362431, 1334229) , X(359046, 1329176) , Y(356436, 1328638) , Z(355184, 1338751) , A1(349193, 1340494) , B1(348154, 1342182) , C1(347646, 1347148) , D1(346657, 1349221) , E1(344812, 1351941) , F1(344553, 1353014) , G1(344254, 1355442) , H1(343192, 1359674) , I1(309854, 1358599) ។

-ផ្ទៃក្រឡាតំបន់ព្រៃការពារអភិរក្សដំរីជំរាលជួរភ្នំក្រវាញភាគកណ្ដាល និង ជីវៈចំរុះ អាចធ្វើការកែប្រែតាមការចាំបាច់ដោយផ្អែកលើពត៌មានវិទ្យាសាស្ត្រ និង ស្ថានភាពជាក់ស្តែង ។ ការកែប្រែនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី២

## ចំណាត់ចាត់ការ

**មាត្រា ៣.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើការរៀបចំ និង គ្រប់គ្រងតំបន់ព្រៃការពារអភិរក្សដំរីជំរាល

ផ្លូវភ្នំក្រវាញភាគកណ្ដាល និង ជីវៈចំរុះ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីធានានូវការអភិវឌ្ឍធនធានធម្មជាតិប្រកបដោយនិរន្តរភាព សំរាប់ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់នោះ ។

## ជំពូកទី៣

## ភារកិច្ច

**មាត្រា ៤.-**

ដំណើរការនៃការរៀបចំ និង ការគ្រប់គ្រងតំបន់ព្រៃការពារអភិរក្សជីជំរាលផ្លូវភ្នំក្រវាញភាគកណ្ដាល និង ជីវៈចំរុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ៥.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្តកោះកុង អភិបាលខេត្តពោធិសាត់ និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តនូវអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៦
- ឯកសារ -កាលប្បវត្តិ